# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 20-Dec-2018, 14:30
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

## ការឆ្លើយតបរបស់លោក ខៀវ សំផន ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខផ្សេងៗ ប្រឆាំងនឹងសាលក្រម ប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨

---

ដាក់ដោយ៖

**មេធាវីការពារក្តីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

ដាក់ជូន៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម

ចៅក្រម Agnieszka KLONOWIECKA-MILART

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Chandra Nihal JAYASINGHE

**ជំនុំជម្រះ**

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Florence Ndepele Mwachande MUMBA

ចៅក្រម យ៉ា ណារិន

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Cécile ROUBEIX

កញ្ញា Marine BOUDJEMAA

កញ្ញា Dounia HATTABI

កញ្ញា ស៊ូស៊ន ច័ន្ទចរិយា

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**មេធាវីការពារក្តីលោក នួន ជា**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូង (“អង្គជំនុំជម្រះ”) នៅក្នុងសវនាការជាសាធារណៈ បានប្រកាសថា លោក ខៀវ សំផន ជាប់ពិរុទ្ធពីបទប្រល័យពូជសាសន៍ (លើជនជាតិវៀតណាម) បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ហើយបានផ្តន្ទាទោសលោក ខៀវ សំផន ឱ្យជាប់ពន្ធនាគារអស់មួយជីវិត[1]។ អង្គជំនុំជម្រះបានបញ្ជាក់ថា សំអាងហេតុពេញលេញនៃសាលក្រម នឹងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ “ក្នុងពេលសមស្របខាងមុខ”[2]។

២. នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ មេធាវីការពារក្តីលោក ខៀវ សំផន (“មេធាវីការពារក្តី”) បានប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ហើយបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូលធ្វើមោឃភាពសាលក្រមដោយមូលហេតុវិការៈទម្រង់ និងគ្មានសំអាងហេតុ (“បណ្តឹងសាទុក្ខ”)[3]។ បណ្តឹងសាទុក្ខនេះត្រូវបានជូនដំណឹងនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨ ។

៣. នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូលនូវការអនុញ្ញាតឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខតែមួយភាសា នៅលើកទី១[4]។ សហព្រះរាជអាជ្ញាបានដាក់ការស្នើសុំពន្យារពេល ដោយហេតុថា *“បណ្តឹងសាទុក្ខទាំង ១៧ ទំព័រ នេះ បានលើកពីបញ្ហាដាច់ដោយឡែកនានាពាក់ព័ន្ធនឹងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក និងការបកស្រាយរបស់វា ដោយមានការយោងដល់ករណីយុត្តិសាស្ត្ររបស់ អ.វ.ត.ក ច្បាប់របស់ប្រទេសកម្ពុជា និងករណីយុត្តិសាស្ត្ររបស់គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប”*[5]។ សំណើនេះត្រូវបានជូនដំណឹងនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅម៉ោង ១៤:៤២។

---

[1] ប្រតិចារឹកសវនាការ (“ប្រតិចារឹក”) ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៨ **E1/529.1** ទំព័រ ៣៩-៤១ ចន្លោះម៉ោង ១១:២៨ និង ១១:៣៥។

[2] ប្រតិចារឹក ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៨ **E1/529.1** ទំព័រ ២-៣ ប្រហែលម៉ោង ៩:៣៦។

[3] បណ្តឹងសាទុក្ខភ្លាមៗរបស់លោក ខៀវ សំផន ប្រឆាំងនឹងសាលក្រម ប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E463/1** (“បណ្តឹងសាទុក្ខ”)។

[4] សំណើរបស់សហព្រះរាជអាជ្ញា សុំដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ តែមួយភាសា ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E463/1/1**។

[5] ដូចខាងលើ កថាខណ្ឌ ២។

៤. នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះតុលាការកំពូលក៏បានឆ្លើយតាមការស្នើសុំពន្យារពេលរបស់សហព្រះរាជអាជ្ញា ហើយបានបង្គាប់អោយដាក់សារណាតបជាភាសាខ្មែរ ត្រឹមថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៨។[6] សេចក្តីសម្រេចនេះត្រូវបានជូនដំណឹង នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅម៉ោង ១៥:៣៥។

៥. នៅថ្ងៃដដែលនេះ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងសាទុក្ខ តែជាភាសាអង់គ្លេសប៉ុណ្ណោះ។ ចម្លើយតបជាភាសាអង់គ្លេសនេះត្រូវបានជូនដំណឹងដល់ភាគី នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៨។[7]

៦. នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ ដោយមិនឃើញមានការជូនដំណឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ជាភាសាខ្មែរ ដែលជាចំណុចចាប់ផ្តើមថិរវេលាសម្រាប់ដាក់ការឆ្លើយតបរបស់ខ្លួន[8] មេធាវីការពារក្តីក៏បានផ្ញើរសារអ៊ីម៉ែលមួយទៅក្រឡាបញ្ជីដើម្បីសួរនាំអំពីហេតុការណ៍។[9]

៧. ដល់ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ម៉ោង ១២:០៧ ដោយនៅតែមិនឃើញមានការជូនដំណឹងពីចម្លើយតបជាភាសាខ្មែររបស់សហព្រះរាជអាជ្ញា និងចម្លើយរបស់ក្រឡាបញ្ជីតបនឹងសារអ៊ីម៉ែលរបស់ខ្លួនកាលពីថ្ងៃទី១២ ខែធ្នូ មេធាវីការពារក្តីក៏បានស្នើសុំសហព្រះរាជអាជ្ញាអោយជួយផ្ញើរសំណៅឯកសារបញ្ជូនក្រៅផ្លូវការដែលពួកគាត់បានដាក់ជាភាសាខ្មែរកាលពីថ្ងៃទី៧ ខែធ្នូ ហើយគួរអោយស្រលាញ់ ពួកគាត់ក៏បានផ្ញើរមកយ៉ាងឆាប់រហ័ស ពោលគឺនៅវេលាម៉ោង ១២:៤៩។[10]

---

[6] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់ចម្លើយតបតែមួយភាសា ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E463/1/1/1**។

[7] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E463/1/2**។ មេធាវីការពារក្តីបានស្នើសុំបកប្រែចម្លើយតប ជាភាសាបារាំង ដែលត្រូវបានជូនដំណឹង នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ ២០១៨។

[8] អនុលោមតាមមាត្រា ៨.៤ និង មាត្រា ៨.៥ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក មេធាវីការពារក្តីមានពេល ៥ ថ្ងៃ ដើម្បីឆ្លើយតប គិតចាប់ពីថ្ងៃជូនដំណឹងអំពីចម្លើយតបជាភាសាអង់គ្លេស និងខ្មែរ។

[9] សារអ៊ីម៉ែលមេធាវីការពារក្តីជូនលោក ស៊ា ម៉ៅ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ ម៉ោង ១៣:៣៥ ដាក់ថា "ការជូនដំណឹងពីចម្លើយតបជាភាសាខ្មែររបស់សហព្រះរាជអាជ្ញាទៅបណ្តឹងសាទុក្ខជាបន្ទាន់របស់លោក ខៀវ សំផន" (មានភ្ជាប់ជាឧបសម្ពន្ធ)។

[10] សារអ៊ីម៉ែលរបស់លោកស្រី Nisha PATEL ជូនមេធាវីការពារក្តី នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ម៉ោង ១២:៤៩ ដាក់ថា "ឆ្លើយតប៖ ចម្លើយតបជាភាសាខ្មែររបស់អស់លោកទៅបណ្តឹងសាទុក្ខជាបន្ទាន់របស់យើងខ្ញុំ (**E463/1/2**)" ដែលបានផ្ញើរមក

៨. នៅថ្ងៃដដែលនោះ មេធាវីការពារក្តីបានផ្ញើរលិខិតមួយច្បាប់ជូនលោកប្រធានអង្គជំនុំជម្រះតុលាការកំពូល ដើម្បីជម្រាបជូនដំណឹងគាត់អំពីស្ថានភាពមិនធ្លាប់ជួបប្រទះ និងដ៏គ្រោះថ្នាក់នៃការជូនដំណឹងយឺតយ៉ាវនេះ ហើយសុំអោយគាត់មេត្តាជួយដោះស្រាយផង។ ជាដំបូង មេធាវីការពារក្តីបានដាក់លិខិតនេះ នៅម៉ោង ១៣:៤៦ បន្ទាប់មក ក៏បានផ្ញើរលិខិតនេះតាមរយៈសារអ៊ីម៉ែលជូនគាត់នៅម៉ោង ១៤:២១។[11] មកទល់ពេលនេះ មិនទាន់មានការជូនដំណឹងពីលិខិតនេះនៅឡើយទេ។[12]

៩. ក្នុងថ្ងៃដដែលនោះ ម៉ោង ១៥:៤៩ មានការជូនដំណឹងចម្លើយតបសហព្រះរាជអាជ្ញានឹងបណ្តឹងសាទុក្ខ ជាភាសា ...អង់គ្លេស។ ដោយសង្ស័យថា ប្រហែលជាមានការភ័ន្តច្រឡំណាមួយ មេធាវីការពារក្តីក៏បានចូលពិនិត្យមើលក្នុងប្រព័ន្ធ *Zylab* ហើយក៏បានរកឃើញចម្លើយតបជាភាសាខ្មែរដែលទើបនឹងត្រូវបានគេដាក់បញ្ចូល។ បើពិនិត្យលើត្រាលើឯកសារ យើងឃើញថា ឯកសារមួយនេះត្រូវបានដាក់ដោយសហព្រះរាជអាជ្ញាកាលពីថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៨ មកម្ល៉េះ (តទៅនេះហៅថា "ចម្លើយតប")។[13]

១០. តាមរយៈសារណានេះ មេធាវីការពារក្តីសូមឆ្លើយតបទៅសហព្រះរាជអាជ្ញា ដែលមិនបង្ហាញថាអង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ដែលនាំឲ្យសាលក្រមមោឃៈ។ ផ្ទុយទៅវិញ ចម្លើយតបរបស់សហព្រះរាជអាជ្ញា ធ្វើឲ្យទឡ្ហីករណ៍ដែលលើកឡើងក្នុងបណ្តឹងសាទុក្ខ កាន់តែមានទម្ងន់ថែមទៀត។ (I) ម៉្យាង ភាពស្ងៀមស្ងាត់របស់សហព្រះរាជអាជ្ញាចំពោះទឡ្ហីករណ៍សំខាន់ៗរបស់មេធាវីការពារក្តី ពិតជាមានន័យច្រើនបំផុត។ (II) ម៉្យាងវិញទៀត ការដែលសហព្រះរាជអាជ្ញាព្យាយាមធ្វើឲ្យការពិភាក្សាមានភាពសាំញ៉ាំ មិនច្បាស់លាស់ ក៏នាំមកនូវពន្លឺជាងគេបំផុតដែរ ។

---

៤២ នាទី ក្រោយពីបានទទួលសំណើមេធាវីការពារក្តី (មានភ្ជាប់ជាឧបសម្ព័ន្ធ)។

[11] សារអ៊ីម៉ែលរបស់មេធាវីការពារក្តីជូនលោក គង់ ស្រ៊ីម នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ម៉ោង ១៤:២១ ដាក់ថា "លិខិតស្តីអំពីការជូនដំណឹងយឺតយ៉ាវ" (មានភ្ជាប់ជាឧបសម្ព័ន្ធ)។

[12] លិខិតជូនលោកប្រធានទាក់ទងនឹងការជូនដំណឹងយឺតយ៉ាវអំពីសេចក្តីសន្និដ្ឋានរបស់ភាគី ថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០១៨ (មានភ្ជាប់ជាឧបសម្ព័ន្ធ)។

[13] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E463/1/2** ("ចម្លើយតប")។

## I. <u>ភាពស្ងៀមស្ងាត់ដ៏មានន័យច្រើនចំពោះទឡ្ហីករណ៍សំខាន់ៗរបស់មេធាវីការពារក្តី</u>

១១. ទោះបីជាសហព្រះរាជអាជ្ញាទទួលបានពេលវេលាបន្ថែមមួយសប្តាហ៍ទៀត សម្រាប់ពិនិត្យលើវិធានផ្ទៃក្នុង ច្បាប់កម្ពុជានានា ព្រមទាំងករណីយុត្តិសាស្ត្រនៃ អ.វ.ត.ក និងករណីយុត្តិសាស្ត្រនៃគណៈកម្មាធិការសិទ្ធិមនុស្សដែលបានបង្ហាញនៅក្នុងបណ្តឹងសាទុក្ខក៏ដោយ ក៏គេសង្កេតឃើញថា សហព្រះរាជអាជ្ញាគ្មានសមត្ថភាពឆ្លើយតប ទៅនឹងទឡ្ហីករណ៍សំខាន់ៗរបស់មេធាវីការពារក្តីឡើយ។

១២. ពីព្រោះថា សហព្រះរាជអាជ្ញានៅស្ងៀមស្ងាត់ចំពោះមុខ៖

១. បទបញ្ញត្តិនានានៃវិធានផ្ទៃក្នុងដែលចែងយ៉ាងជាក់ច្បាស់បំផុតអំពីការដែលថា សាលក្រមត្រូវតែចុះហត្ថលេខា "យ៉ាងយូរបំផុត" នៅថ្ងៃប្រកាសសាលក្រម ត្រូវប្រគល់ច្បាប់ចម្លងនៃសាលក្រមជូនដល់ភាគី ហើយត្រូវបោះពុម្ពផ្សាយនៅថ្ងៃប្រកាសសាលក្រម ហើយថាកាលកំណត់បណ្តឹងសាទុក្ខចាប់រាប់ពីពេលប្រកាសសាលក្រមដូចគ្នាក្នុងច្បាប់កម្ពុជាដែរ[14]។

២. តាមរយៈករណីយុត្តិសាស្ត្រនៃតុលាការកំពូល ស្របតាមក្របខណ្ឌគតិយុត្តិនៃ អ.វ.ត.ក សាលក្រមត្រូវតែប្រកាសជាជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ បើពុំនោះទេ នឹងត្រូវទុកជាមោឃៈ[15] ។

៣. ការបាត់បង់សិទ្ធិរបស់ចៅក្រមនៃអង្គជំនុំជម្រះ នៅពេលដែលប្រកាសសាលក្រមរួចហើយ ធ្វើឲ្យសំអាងហេតុជាលាយលក្ខណ៍អក្សរនៃសាលក្រម ដែលធ្វើឡើងក្រោយពេលប្រកាសគ្មានសុពលភាព ដោយសារតែខ្វះយុត្តាធិការ[16]។

១៣. ដើម្បីបិទបាំងអសមត្ថភាពរបស់ខ្លួនក្នុងការឆ្លើយតប សហព្រះរាជអាជ្ញាព្យាយាមបង្វែរការយកចិត្តទុកដាក់របស់អង្គជំនុំជម្រះតុលាការកំពូល ដោយប្រើប្រាស់វិធីចាស់គម្រិល គឺបំភ្លៃពាក្យពេចន៍របស់មេធាវីការពារក្តី ដោយឆ្លើយតបជាមួយនឹងអំណះអំណាងមិនពាក់ព័ន្ធ ដែលច្រើនតែខុស តែ

[14] បណ្តឹងសាទុក្ខ កថាខណ្ឌ ៦-៧, ១៥-១៦, ៥៩។

[15] បណ្តឹងសាទុក្ខ កថាខណ្ឌ ៥៦-៥៨។

[16] បណ្តឹងសាទុក្ខ កថាខណ្ឌ ៣៧, ៤៤-៤៥, ៤៨-៥០។

បន្ថែមល្បែយដោយប្រើរូបមន្តវន្ធត់ចិត្ត ក្នុងបំណងចោទប្រកាន់លើរូបលោក ខៀវ សំផន ថា ជាមនុស្សទុច្ចរិត[17]។

## II. ការព្យាយាមយ៉ាងជាក់ច្បាស់ក្នុងការធ្វើឲ្យការពិភាក្សានៅជាខ្ទៅងងឹត

១៤. សហព្រះរាជអាជ្ញាព្យាយាមប្រើវិធីបំភ័ន្តភ្នែកនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ជាពិសេសដោយ (១) បង្វែរការពិភាក្សាស្តីពីដីកាកំណត់កាលបរិច្ឆេទនៃការប្រកាសសាលក្រម (២) ដោយផ្តល់ជូនអង្គជំនុំជម្រះនូវអំណាចប្រឌិតក្លែងក្លាយ ឬអំណាចវេទមន្ត និង (៣) ដោយព្យាយាមរារាំងមិនឲ្យឃើញព្យសនកម្មដែលទទួលរងដោយលោក ខៀវ សំផន ។

## ១. ដីកាកំណត់កាលបរិច្ឆេទប្រកាសសាលក្រម គឺទល់នឹង ផ្នែកសម្រេចសេចក្តី

១៥. បើតាមសហព្រះរាជអាជ្ញា បណ្តឹងសាទុក្ខមានភាពយឺតយ៉ាវ ពីព្រោះលោក ខៀវ សំផន គួរតែជំទាស់ទៅនឹងដីកាកំណត់កាលបរិច្ឆេទប្រកាសសាលក្រមចំពោះមុខអង្គជំនុំជម្រះ ឬ ដាក់បណ្តឹងសាទុក្ខចំពោះមុខតុលាការកំពូល ជាជាងរង់ចាំការប្រកាសសាលក្រម[18]។ ក៏ប៉ុន្តែ លោក ខៀវ សំផន មិនអាចជំទាស់ទៅនឹងដីកាកំណត់កាលបរិច្ឆេទប្រកាសសាលក្រម ហើយក៏មិនអាចដាក់បណ្តឹងសាទុក្ខដែរ។

១៦. ជាដំបូង វិធាននៃផ្ទៃក្នុងបានចែងយ៉ាងជាក់ច្បាស់ថា នៅពេលពិភាក្សាសម្រេចសេចក្តី (ដែលបន្តរហូតដល់ពេលចេញសាលក្រម) កិច្ចពិភាក្សាដេញដោលត្រូវបានបិទបញ្ចប់ ហើយភាគីមិនអាចដាក់សំណើសុំចំពោះមុខអង្គជំនុំជម្រះទៀតឡើយ[19]។

១៧. បន្ទាប់មក ដីកានេះមិនអនុញ្ញាតឲ្យមានបណ្តឹងសាទុក្ខភ្លាមៗចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលឡើយ។ ផ្ទុយពីការអះអាងរបស់សហព្រះរាជអាជ្ញា[20] ដីកាកំណត់កាលបរិច្ឆេទប្រកាសសាលក្រម

---

[17] ឧទាហរណ៍៖ "ខៀវ សំផន លើកហេតុផលអំពីចរិតអាក្រក់របស់អង្គជំនុំជម្រះសាលាដំបូង" (*« nefarious motives »* នៅក្នុងច្បាប់ដើម ចម្លើយតប កថាខណ្ឌ ១)។ ឬ៖ "ការណ៍នេះ (...) បង្ហាញដោយខុសឆ្គងដោយចេតនា (...)" (ចម្លើយតប កថាខណ្ឌ១៧) ខណៈដែលមេធាវីការពារក្តីមិនធ្លាប់បានអះអាងបែបនេះទេ (បណ្តឹងសាទុក្ខ)។

[18] ចម្លើយតប កថាខណ្ឌ ៦ និងកថាខណ្ឌ ២០។

[19] វិធាន ៩២ និងវិធាន ៩៦(២) នៃវិធានផ្ទៃក្នុង។

នេះមិនមែនជាសេចក្តីសម្រេចដែលត្រូវបញ្ចប់កិច្ចដំណើរការនីតិវិធី ហើយក៏មិនមែនជាសេចក្តីសម្រេចស្តីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះដែរ។ ម៉្យាងទៀត សហព្រះរាជអាជ្ញាបាននិយាយជាន់កែងឯង ដោយបានអះអាងថា "សេចក្តីសម្រេចផ្នែកនីតិវិធីទាក់ទងនឹងពេលវេលានៃការប្រកាសសាលក្រម និងសាលក្រមជាលាយលក្ខណ៍អក្សរនៅពេលខាងមុខ មិនមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធីទេ ពាក់ព័ន្ធនឹងការចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ ទោះជាមួយផ្នែក ឬទាំងស្រុងក៏ដោយ"[21]។ ជាក់ស្តែង មានតែសាលក្រមដែលបានប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ដែលលោក ខៀវ សំផន បានដាក់បណ្តឹងសាទុក្ខប៉ុណ្ណោះ ទើបអាចបញ្ចប់នីតិវិធីទាំងស្រុង ឬដោយផ្នែកចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

១៨. សហព្រះរាជអាជ្ញាព្យាយាមធ្វើឱ្យគេជឿថា សាលក្រមដែលបានប្រកាសរួច មិនមានសារៈសំខាន់ឡើយ ថា មិនមែនជាសាលក្រមទេ ហើយថា មានតែ "សាលក្រមជាលាយលក្ខណ៍អក្សរ" ប៉ុណ្ណោះ ទើបអាចបើកផ្លូវបណ្តឹងសាទុក្ខ[22]។ ក៏ប៉ុន្តែ ដូចដែលមេធាវីការពារក្តីបានរម្លឹកច្បាស់លាស់រួចមកហើយ ការដាក់ផ្នែកសម្រេចសេចក្តីនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ គឺមានន័យថាអង្គជំនុំជម្រះបានចេញសេក្តីសម្រេចរបស់ខ្លួនរួចហើយ[23]។ លើសពីនោះទៀត ថិរវេលាកំណត់សម្រាប់បណ្តឹងសាទុក្ខ ចាប់ផ្តើមគិតពីថ្ងៃប្រកាសសាលក្រម[24]។ ម៉្យាងទៀត វិធាន ១០៧(៤) នៃវិធានផ្ទៃក្នុង បានលើកឡើងពីការប្រកាសបណ្តឹងសាទុក្ខ "ប្រឆាំងនឹងសាលក្រមដែលបាន**<u>ប្រកាស</u>**ដោយអង្គជំនុំជម្រះ"[25] មិនមែនប្រឆាំងនឹង "សាលក្រមជាលាយលក្ខណ៍អក្សរ"[26] ឬប្រឆាំងនឹង "សាលក្រមមានសម្អាងហេតុយ៉ាងពេញលេញ"[27] ដែលចេញនៅពេលក្រោយនោះទេ។

---

[20] ចម្លើយតប កថាខណ្ឌ ៦ និងកំណត់សម្គាល់ជើងទំព័រ ១៣ ដែលយោងទៅវិធាន ១០៧(១) នៃវិធានផ្ទៃក្នុង ដែលយោងទៅវិធាន ១០៤(៤)(ក) ("សេចក្តីសម្រេចដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី") និង វិធាន ១០៤(៤)(ឃ) ("សេចក្តីសម្រេចស្តីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ តាមវិធាន ៣៥(៦)"។

[21] ចម្លើយតប កថាខណ្ឌ ១០។

[22] ចម្លើយតប កថាខណ្ឌ ១១, ១៧ និង ២២។

[23] បណ្តឹងសាទុក្ខ កថាខណ្ឌ ១១, ៣៧។

[24] បណ្តឹងសាទុក្ខ កថាខណ្ឌ ១៥-១៧។

[25] បណ្តឹងសាទុក្ខ កថាខណ្ឌ ១៥ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[26] ចម្លើយតប កថាខណ្ឌ ១១ និងកថាខណ្ឌ ២២។

[27] ចម្លើយតប កថាខណ្ឌ ២២។

១៩. នៅក្នុងវាក្យស័ព្ទច្បាប់ ផ្នែកសម្រេចសេចក្តីត្រូវបានកំណត់និយមន័យថាជា "ផ្នែកចុងបញ្ចប់នៃ *សាលក្រម* ដែលរួមមានសេចក្តីសម្រេចរបស់ចៅក្រម និង *"អាជ្ញាអស់ជំនុំ"*[28] ភ្ជាប់ជាមួយផង។ ដូច្នេះ ផ្នែកសម្រេចសេចក្តី គឺពិតជា "សាលក្រមផ្ទាល់តែម្តង" ដូចមានចែងក្នុងវិធាន ១០១(១)(ខ) នៃវិធានផ្ទៃក្នុង ហើយផ្នែកសម្រេចសេចក្តីនេះបង្កើតអានុភាពដែលផ្សារភ្ជាប់ទៅនឹងសាលក្រម។

២០. ដោយហេតុថាផ្នែកសម្រេចសេចក្តីគ្របដណ្តប់ទៅលើអាជ្ញាអស់ជំនុំ នៅក្នុងសំណុំរឿង ០០៤/០១ អង្គបុរេជំនុំជម្រះបានរំឭកថា ចៅក្រមស៊ើបសួរបានច្រានចោលសំណុំរឿងភ្លាមៗបន្ទាប់ពីបាន ចេញផ្នែកសម្រេចសេចក្តីនៃដីកាដំណោះស្រាយរួចហើយ[29]។ ដោយហេតុថាផ្នែកសម្រេចសេចក្តី គ្របដណ្តប់ទៅលើអាជ្ញាអស់ជំនុំ នៅក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះទទួលបណ្តឹងតាមរយៈ សាលក្រមនៃអង្គបុរេជំនុំជម្រះស្តីពីបណ្តឹងសាទុក្ខប្រឆាំងនឹងដីកាដំណោះស្រាយ ដែលមានតែផ្នែក សម្រេចសេចក្តី[30]។

២១. ផ្នែកសម្រេចសេចក្តីដែលបានប្រកាស នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ គ្របដណ្តប់ទៅលើអាជ្ញា អស់ជំនុំ។ ខុសពីដីកាកំណត់កាលបរិច្ឆេទ[31] ផ្នែកសម្រេចសេចក្តីនេះមិនត្រូវបានចេញ ដើម្បីទុកជា ការជូនជាដំណឹងនោះឡើយ។

២២. ដោយប្រកាសផ្នែកសម្រេចសេចក្តីនៃសាលក្រម មានន័យថាអង្គជំនុំជម្រះបានចេញសាលក្រម របស់ខ្លួននៅក្នុងសំណុំរឿង ០០២/០២។ អង្គជំនុំជម្រះបានសម្រេចលើពិរុទ្ធភាព ឬអពិរុទ្ធភាព របស់ជនជាប់ចោទ ចំពោះអង្គហេតុមួយផ្នែកដែលមានចែងនៅក្នុងសេចក្តីសម្រេចបញ្ជូនរឿងទៅ

---

[28] វចនានុក្រមវាក្យស័ព្ទច្បាប់ ក្រោមការដឹកនាំរបស់លោក Rémy Cabrillac គ្រឹះស្ថានរៀបរៀង LexisNexis Litec បោះពុម្ព លើកទី៣ (ឆ្នាំ ២០០៨) ទំព័រ ១៩៩ (គូសបន្ទាត់ពីក្រោមក្នុងច្បាប់ដើម មានភ្ជាប់ក្នុងឧបសម្ព័ន្ធ)។

[29] បណ្តឹងសាទុក្ខ កថាខណ្ឌ ៤៥។

[30] បណ្តឹងសាទុក្ខ កថាខណ្ឌ ៤៥១ និងកំណត់សម្គាល់ជើងទំព័រ ២១។

[31] វិធាន ៩៨(១) នៃវិធានផ្ទៃក្នុង៖ "នៅពេលដែលសាលក្រមមិនត្រូវបានប្រកាសក្នុងពេលសវនាការចុងក្រោយទេ ប្រធានអង្គជំនុំ ជម្រះត្រូវជូនដំណឹងដល់ភាគីអំពីការកំណត់កាលបរិច្ឆេទ ដើម្បីប្រកាសសាលក្រម"។ នៅក្នុងដីកាកំណត់កាលបរិច្ឆេទប្រកាស សាលក្រម ចេញ "អនុលោមតាមវិធាន ៩៨ នៃវិធានផ្ទៃក្នុង" អង្គជំនុំជម្រះបាន "ជូនដំណឹង" ដល់ភាគីនានាអំពីកាលបរិច្ឆេទនៃ ការប្រកាសសាលក្រម ហើយអង្គជំនុំជម្រះនឹងជូនដំណឹងអំពីសម្អាងហេតុពេញលេញនៃសាលក្រមនេះ នៅក្នុងពេលវេលាមួយ សមស្រប (ដីកាកំណត់កាលបរិច្ឆេទប្រកាសសាលក្រមនៅក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ ២០១៨ ឯកសារ **E462** ទំព័រ ២)។

ជំនុំជម្រះ ហើយបានផ្តន្ទាទោសជនជាប់ចោទឲ្យជាប់ពន្ធនាគារអស់មួយជីវិត។ ចិរវេលានៃបណ្តឹងសាទុក្ខចាប់ផ្តើមគិត កិច្ចដំណើការនីតិវិធីនៃអង្គជំនុំជម្រះត្រូវបានបិទបញ្ចប់ ហើយអង្គជំនុំជម្រះក៏ត្រូវដកខ្លួនចេញពីសំណុំរឿង។

២៣. ដូច្នេះ ឥឡូវនេះ វាដល់ពេលដែលអង្គជំនុំជម្រះតុលាការកំពូលត្រូវចូលអន្តរាគមន៍ និងប្រកាសបណ្តឹងសាទុក្ខ ដែលតុលាការវាយតម្លៃថាជាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ឬបណ្តឹងភ្លាមៗប្រឆាំងនឹងសាលក្រមដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី។ អង្គជំនុំជម្រះតុលាការកំពូលក៏អាចជ្រើសរើសការអនុវត្តយុត្តាធិការជាប់មកជាមួយ ទោះបីមានអំណះអំណាងផ្ទុយពីសំណាក់សហព្រះរាជអាជ្ញាដែលយល់ថា "បច្ចុប្បន្ននេះ មិនមានកិច្ចដំណើរការនីតិវិធីផ្ទាល់នៅចំពោះមុខ[អង្គជំនុំជម្រះតុលាការកំពូល]"[32] យ៉ាងណាក៏ដោយ។ ពីព្រោះថា ថ្មីៗនេះ ស្ថានភាពបែបនោះមិនបានរារាំងអង្គបុរេជំនុំជម្រះមិនឲ្យអនុវត្តយុត្តាធិការជាប់ខ្លួន ក្នុងការសម្រេចលើសំណើសុំដែលបានដាក់ជូននៅក្នុងសំណុំរឿង ០០៤/២ នោះឡើយ[33]។

២៤. ដើម្បីបិទបាំងឱ្យបានប្រសើរនូវអំណាចអន្តរាគមន៍ជាក់ស្តែងរបស់អង្គជំនុំជម្រះតុលាការកំពូល សហព្រះរាជអាជ្ញាបានផ្តល់ជូនអង្គជំនុំជម្រះនូវអំណាចប្រឌិតមួយចំនួន។

## ២. ការផ្តល់អំណាចប្រឌិតដល់អង្គជំនុំជម្រះ

២៥. សហព្រះរាជអាជ្ញាបានផ្តល់ជូនអង្គជំនុំជម្រះនូវអំណាចប្រឌិតមួយចំនួនដែលខ្លួនគ្មាន គឺ (ក) អំណាចក្នុងការយកលំនាំតាមតុលាការព្រហ្មទណ្ឌអន្តរជាតិ នូវទម្រង់ការនៃសាលក្រម (ខ)

---

[32] ចម្លើយតប កថាខណ្ឌ ១៣។

[33] សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំការកោសលុប និងការចាត់វិធានការបណ្តោះអាសន្ន ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ ឯកសារ **D360/3** កថាខណ្ឌ ៦៖ "អង្គបុរេជំនុំជម្រះសូមរម្លឹកថា ការិយាល័យសហចៅក្រមស៊ើបអង្កេត*បំពេញតួនាទីរបស់ខ្លួនចប់សព្វគ្រប់ហើយ* ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៤/០២ ចាប់តាំងពីពេលចេញដីកាដំណោះស្រាយមកម្ល៉េះ។ ទោះបីជាអង្គបុរេជំនុំជម្រះបានទទួលសំណើសុំបច្ចុប្បន្ននេះក៏ដោយ ក៏ការិយាល័យតុលាការផ្សេងទៀតពុំបានទទួលសំណុំរឿងនេះជាផ្លូវការនៅឡើយទេ (...) ដោយហេតុថាបណ្តឹងឧទ្ធរណ៍ពុំទាន់ឃើញបានដាក់មកនៅឡើយ។ (...) អង្គបុរេជំនុំជម្រះយល់ឃើញថាវាមានលក្ខណៈសមស្រប ក្នុងការអនុវត្តយុត្តាធិការដែលខ្លួនទទួលបាន ក្នុងនាមជាអង្គជំនុំជម្រះទទួលបណ្តឹងឧទ្ធរណ៍នៅដំណាក់កាលមុនអង្គសេចក្តី និងនៅពេលពុំមានសេចក្តីសម្រេចជាក់លាក់ណាមួយសម្រេចលើសំណើសុំនេះដើម្បីផលប្រយោជន៍នៃយុត្តិធម៌"។

អំណាចឆន្ទានុសិទ្ធិក្នុងការវាំលោភបំពានលើវិធាននៃផ្ទៃក្នុង (គ) អំណាចក្នុងការកំណត់ថិរវេលានៃបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់ខ្លួន។

ក. <u>អំណាចក្នុងការយកលំនាំតាមតុលាការព្រហ្មទណ្ឌអន្តរជាតិ</u>

២៦. សហព្រះរាជអាជ្ញាអះអាងថា អង្គជំនុំជម្រះមិនបានប្រព្រឹត្តកំហុសឡើយ បើពិនិត្យមើលការអនុវត្តរបស់អង្គជំនុំជម្រះនៃ អ.វ.ត.ក ក្នុងការចេញ ផ្នែកសម្រេចសេចក្តីក្នុងដំណាក់កាលទីមួយ និងសំអាងហេតុក្នុងដំណាក់កាលទីពីរ "នៅពេលបោះពុម្ពផ្សាយសាលក្រម និងសេចក្តីសម្រេចរបស់ពួកគេ"[34]។ មេធាវីការពារក្តីបានពន្យល់យ៉ាងវែងថា ការអនុវត្តបែបនេះមិនត្រូវបានអនុញ្ញាតក្នុងសាលក្រមឡើយ (ដែលលើកឡើងពីពិរុទ្ធភាពនៃជនជាប់ចោទ)[35] ហើយសហព្រះរាជអាជ្ញាគ្មានសមត្ថភាពក្នុងការរកឱ្យឃើញនូវការអនុវត្តបែបនេះមុនៗនៅ អ.វ.ត.ក ឡើយ។

២៧. ដូច្នេះ សហព្រះរាជអាជ្ញាក៏បានបន្ថែមថា មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពី អ.វ.ត.ក អនុញ្ញាតឱ្យអង្គជំនុំជម្រះយកលំនាំតាមតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលបានអនុញ្ញាតយ៉ាងជាក់ច្បាស់ពីការអនុវត្តនោះនៅក្នុងសាលក្រម[36]។

២៨. ក៏ប៉ុន្តែ មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពី អ.វ.ត.ក ចែងថា ៖

"អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅ<u>**ឱ្យបានត្រឹមត្រូវ**</u> និងឆាប់រហ័សទៅ<u>**តាមនីតិវិធីជាធរមាន**</u> ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និងមានការការពារឱ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ និងសាក្សី។ ប្រសិនបើនីតិវិធី ដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។ អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ

---

[34] ចម្លើយតប កថាខណ្ឌ ១៦។

[35] បណ្តឹងសាទុក្ខ កថាខណ្ឌ ៣៩-៥០។

[36] ចម្លើយតប កថាខណ្ឌ ១៦។

<u>ភាពត្រឹមត្រូវនឹងដំណើរការសមស្របនៃច្បាប់</u> ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃ អនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ" (យើងខ្ញុំជាអ្នកគូសបន្ទាត់)។

២៩. ក្នុងករណីនេះ វិធានផ្ទៃក្នុង "ដែលមានកម្មវត្ថុក្នុងការសំយោគលើដំណើរការនីតិវិធីកម្ពុជាសម្រាប់អនុវត្តក្នុងរឿងក្តីនៅ អ.វ.ត.ក"[37] បានលើកឡើងយ៉ាងច្បាស់លាស់ពីបញ្ហាទម្រង់ការនៃសាលក្រម និងចំណុចចាប់ផ្តើមនៃថិរវេលាបណ្តឹងសាទុក្ខ៖ សាលក្រមត្រូវមានសំអាងហេតុ ហើយត្រូវដាក់ជាលាយលក្ខណ៍អក្សរនៅថ្ងៃប្រកាសសាលក្រម ដែលជាចំណុចចាប់ផ្តើមនៃថិរវេលាបណ្តឹងសាទុក្ខ[38]។ មិនមានភាពស្រពិចស្រពិលសោះឡើយនៅក្នុងការបកស្រាយបទបញ្ញត្តិ ឬក្នុងការអនុវត្តបទបញ្ញាណាមួយក្នុងច្បាប់កម្ពុជា ហើយភាពស្របគ្នារវាងច្បាប់កម្ពុជា និងបទដ្ឋានអន្តរជាតិ មិនចោទជាបញ្ហាឡើយ។ ផ្ទុយទៅវិញ ដំណើរការនីតិវិធីជាធរមានស្តីពីទម្រង់ការនៃសាលក្រម ត្រូវអនុលោមទៅតាមមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ហើយជាក់លាក់ជាងនោះទៀត គឺកថាខណ្ឌ ១ និងកថាខណ្ឌ ៥[39]។

៣០. ដូច្នេះ អង្គជំនុំជម្រះមិនមានអំណាចណាមួយក្នុងការយកតាមលំនាំតុលាការព្រហ្មទណ្ឌអន្តរជាតិចំពោះទម្រង់ការនៃសាលក្រមឡើយ។ អង្គជំនុំជម្រះមិនត្រូវបានចងភ្ជាប់ដោយវិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិទាំងនោះទេ តែដោយវិធានផ្ទៃក្នុងនៃ អ.វ.ត.ក ។ លោក ខៀវ សំផន ទទួលបានការវិនិច្ឆ័យទោសនៅប្រទេសកម្ពុជា ចំពោះមុខ អ.វ.ត.ក មិនមែនចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិនោះឡើយ។ អនុលោមតាមគោលការណ៍ភាពអាចប្រមើលមើលបាន និងគោលការណ៍សច្ចភាពផ្លូវច្បាប់ លោកមានសិទ្ធិរង់ចាំឲ្យច្បាប់នៃ អ.វ.ត.ក ត្រូវយកមកអនុវត្តចំពោះរូបលោក ហើយមានតែច្បាប់នោះមួយគត់ដែលអាចអនុវត្តលើរូបលោកបាន។

៣១. ពេល អ.វ.ត.ក អនុម័តវិធានផ្ទៃក្នុង នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ តុលាការនេះបានជ្រើសរើសការមិនយកលំនាំតាមបទបញ្ញត្តិ ដែលអនុម័តដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ តាំងពីឆ្នាំ១៩៩៥ ទាក់ទិននឹងទម្រង់ការនៃសាលក្រម[40]។ ផ្ទុយទៅវិញ អ.វ.ត.ក បានជ្រើសរើសយកការបង្ខំឲ្យអង្គ

---

[37] វិធានផ្ទៃក្នុង បុព្វកថា ទំព័រ ៨ ត្រង់ពាក្យ "ដោយហេតុថា" ចុងក្រោយ។

[38] បណ្តឹងសាទុក្ខ កថាខណ្ឌ ៥-៧ និងកថាខណ្ឌ ១៥-១៦។

[39] វិធាន ១៤(១)៖ "គ្រប់សាលក្រមទាំងអស់ត្រូវតែប្រកាសនៅពេលសវនាការជាសាធារណៈ" វិធាន ១៤(៥) ស្តីពីបណ្តឹងសាទុក្ខ បណ្តឹងសាទុក្ខ កថាខណ្ឌ ៥៨-៥៩។

[40] <u>វិធានស្តីពីនីតិវិធី និងភ័ស្តុតាង នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី</u> វិធាន ៩៨ ស្ទួនពីរ (ក) និង

ជំនុំជម្រះចេញសាលក្រម ដោយមានសំអាងហេតុជាលាយលក្ខណ៍អក្សរ "យ៉ាងយូរ" នៅថ្ងៃប្រកាសសាលក្រម។

៣២. នៅពេលដែល អ.វ.ត.ក បានកែប្រែវិធានផ្ទៃក្នុងរបស់ខ្លួន នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១ ដើម្បីអនុញ្ញាតឲ្យតុលាការកំពូលដាក់សំអាងហេតុពេញលេញនៅពេលក្រោយ ក្នុងករណីមានសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗ[41] អ.វ.ត.ក ក៏បានសម្រេចមិនអនុញ្ញាតឲ្យអង្គជំនុំជម្រះធ្វើបែបនោះក្នុងការចេញសាលក្រមឡើយ។

៣៣. រហូតដល់ថ្ងៃនេះ អ.វ.ត.ក បានសម្រេចបង្ខំឲ្យអង្គជំនុំជម្រះចេញសាលក្រម ដោយមានសំអាងហេតុជាលាយលក្ខណ៍អក្សរ "យ៉ាងយូរបំផុត" នៅថ្ងៃប្រកាសសាលក្រម និងសម្រេចគិតថិរវេលាបណ្ដឹងសាទុក្ខចាប់ពីថ្ងៃប្រកាសសាលក្រម។ អង្គជំនុំជម្រះត្រូវអនុវត្តដោយអនុលោមទៅតាមជម្រើសនោះ ហើយបើយោងជាថ្មីទៅនឹងស្មារតីនៃមាត្រា ៣៣ ថ្មី នៃច្បាប់បង្កើត អ.វ.ត.ក ដែលបានស្រង់សម្ដីខាងលើ អង្គជំនុំជម្រះត្រូវអនុវត្ត "ស្របតាមនីតិវិធីជាធរមាន" និង "ដោយគោរពទម្រង់ការធម្មតា"។ ផ្ទុយពីការអះអាងរបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះមិនមានជម្រើសអ្វីផ្សេងសោះឡើយក្នុងកិច្ចការនេះ។

ខ. <u>អំណាចឆន្ទានុសិទ្ធិក្នុងការរំលោភលើវិធានផ្ទៃក្នុង</u>

៣៤. តបទៅនឹងមេធាវីការពារក្ដី ដែលលើកឡើងពីកំហុសអង្គច្បាប់ដែលនាំឲ្យសាលក្រមមោឃៈ និងព្យសនកម្មដែលទទួលរងដោយសារតែកំហុសនេះ[42] សហព្រះរាជអាជ្ញាឆ្លើយថា អង្គជំនុំជម្រះមិនបានប្រព្រឹត្តកំហុសដែលស្ដែងចេញពីការប្រើឆន្ទានុសិទ្ធិ ដែលនាំឲ្យមានការប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្ដឹងសាទុក្ខនោះទេ។ សហព្រះរាជអាជ្ញាអះអាងថា អង្គជំនុំជម្រះតុលាការកំពូលបាន

---

(គ) ដែលត្រូវបានដាក់បញ្ចូលជាមាត្រា ៨៨(ក) និង (គ) ក្នុងសំណៅកែប្រែ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩៥, <u>វិធានស្ដីពីនីតិវិធី និងភ័ស្តុតាង នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា</u> វិធាន ៨៨(ក) និង (គ) មានវត្តមានតាំងពីកំណែលើកទី ១ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៩៥, <u>វិធានស្ដីពីនីតិវិធី និងភ័ស្តុតាង នៃតុលាការពិសេសសម្រាប់ប្រទេសលីបង់</u> វិធាន ១៦៨(ក) និង (ខ) មានវត្តមានតាំងពីកំណែ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៩, <u>វិធានស្ដីពីនីតិវិធី និងភ័ស្តុតាង នៃយន្តការសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ</u> វិធាន ១២២(ក) និង (គ) មានវត្តមានតាំងពីកំណែលើកទី ១ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១២។

[41] បណ្ដឹងសាទុក្ខ កថាខណ្ឌ ៤០ និងកំណត់សម្គាល់ជើងទំព័រ ១៦។

[42] បណ្ដឹងសាទុក្ខ កថាខណ្ឌ ៤, ៣៣, ៥៤, ៥៥-៦៨។

"កត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូង ជាញឹកញាប់ បានរីករាយនឹងឆន្ទានុសិទ្ធិទាក់ទងនឹងបញ្ហានីតិវិធីនានា" និងបានកំណត់យកវិធីសាស្ត្រប្រកបដោយភាពប្រយ័ត្នប្រយែងលើបញ្ហានេះ[43]។

៣៥. ពិតមែនតែ "ជាញឹកញាប់" បញ្ហានីតិវិធីស្ថិតក្រោមអំណាចឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ ប៉ុន្តែ វាមិនមែនគ្រប់ករណីទាំងអស់នោះទេ ហើយប្រាកដណាស់ វាមិនមែនជាករណីពាក់ព័ន្ធនឹងទម្រង់ការនៃសាលក្រមនោះឡើយ។

៣៦. ការអនុវត្តអំណាចឆន្ទានុសិទ្ធិ សន្មតជាមុនអំពីលទ្ធភាពក្នុងការធ្វើជម្រើសអ្វីមួយ។ ខុសពីអ្នកតាក់តែងវិធាននីតិវិធី និងភ័ស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ អ្នកតាក់តែងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក មិនបានទុកឆន្ទានុសិទ្ធិជូនអង្គជំនុំជម្រះ ដើម្បីជ្រើសរើសកិច្ចដំណើរការនីតិវិធីផ្សេងគ្នាសម្រាប់ចេញសាលក្រមឡើយ។

៣៧. ម្យ៉ាងវិញទៀត និងទោះជាក្នុងករណីណាក៏ដោយ អំណាចឆន្ទានុសិទ្ធិមិនមែនគ្មានដែនកំណត់នោះទេ ហើយមិនមែនមានន័យថា ចៅក្រមមានសិទ្ធិរំលោភលើវិធានជាធរមានស្រេចតែនឹងចិត្ត និងធ្វើអ្វីតាមទំនើងចិត្តនោះឡើយ។

៣៨. ដើម្បីឆ្លុះបញ្ចាំងជាក់ស្តែងអំពីគោលការណ៍គតិយុត្តិជាមូលដ្ឋានទាំងនេះ យើងគ្រាន់តែអានសេចក្តីដកស្រង់ចេញពីយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល ដែលសហព្រះរាជអាជ្ញាលើកយកមកធ្វើជាសំអាង៖

"**យោងតាមខ្លឹមសារនៃវិធាន ៣៥(១) និងវិធាន ៣៥(២)** នៃវិធានផ្ទៃក្នុង ចៅក្រម និងអង្គជំនុំជម្រះមាន**ឆន្ទានុសិទ្ធិសម្រេច**ថា តើមធ្យោបាយផ្នែកនីតិវិធីអ្វីដែលត្រូវអនុវត្តដើម្បីប្រឆាំងនឹងអំពើនៃការជ្រៀតជ្រែក *ដែលបញ្ជាក់ដំបូង* ចូលក្នុងកិច្ចការរដ្ឋបាលតុលាការ ហើយពួកគេ**មានសិទ្ធិសម្រេច**នៅក្នុងដែនកំណត់នៃឆន្ទានុសិទ្ធិរបស់ខ្លួនថា តើត្រូវចាត់វិធានការនីតិវិធីណាមួយ ឬអត់ ទោះបីជាក្នុងករណីដែលពួកគាត់អាចជឿថាការជ្រៀតជ្រែកបានកើតឡើងមែននោះ" (យើងខ្ញុំជាអ្នកដាក់អក្សរដិត)

[43] ចម្លើយតប កថាខណ្ឌ ១៩។

"ក៏អង្គជំនុំជម្រះនឹងនៅតែស្ថិត**នៅក្នុងដែនកំណត់នៃឆន្ទានុសិទ្ធិរបស់ខ្លួន** ក្នុងការបដិសេធមិនធ្វើការស៊ើបអង្កេតបែបនោះឡើយ"[44] (យើងខ្ញុំជាអ្នកដាក់អក្សរដិត)។

៣៩. នៅក្នុងករណីនេះ យោងតាមខ្លឹមសារនៃបទប្បញ្ញត្តិនៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះពុំមានអំណាចឆន្ទានុសិទ្ធិអ្វីទេ ពាក់ព័ន្ធនឹងទម្រង់ការ និងការប្រកាសសាលក្រម។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះតុលាការកំពូលបានយល់ច្បាស់ពីចំណុចនេះ ដោយបានរម្លឹកថា យោងតាមក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ខុសពីសេចក្តីសម្រេចផ្សេងទៀត សាលក្រមត្រូវតែចេញជាលាយលក្ខណ៍អក្សរ បើពុំនោះសោតទេ ត្រូវទុកជាមោឃៈ[45]។ អាស្រ័យហេតុនេះ ដោយសារតែបានរំលោភលើវិធានផ្ទៃក្នុង អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ដែលនាំឱ្យសាលក្រមមោឃៈ។

គ. <u>អំណាចក្នុងការកំណត់ពេលវេលាធ្វើបណ្តឹងសាទុក្ខ</u>

៤០. ផ្ទុយពីការអះអាងរបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះពុំមានអំណាចវេទមន្ត ដើម្បីកំណត់ពេលវេលាធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម (ឬប្រឆាំងនឹងសេចក្តីសម្រេចផ្សេងទៀត) របស់ខ្លួនឡើយ។

៤១. សហព្រះរាជអាជ្ញាលើកឡើងថា ខៀវ សំផន "មិនអើពើ" នឹងការថ្លែង "យ៉ាងច្បាស់លាស់" របស់អង្គជំនុំជម្រះក្រោយពេលប្រកាសសាលក្រម ស្តីពីរយៈពេលកំណត់សម្រាប់ការដាក់បណ្តឹងសាទុក្ខដែលនឹងត្រូវចាប់ផ្តើមរាប់ក្រោយពីការជូនដំណឹងអំពីសាលក្រមដែលមានសំអាងហេតុពេញលេញជាពីរភាសាការងាររបស់ភាគី[46]។ សហព្រះរាជអាជ្ញាអះអាងថា អង្គជំនុំជម្រះធ្វើបែបនេះ ដោយអនុវត្តវិធាន ១០១(៦)(ឈ) វិធាន ១០៧(៤) វិធាន ៣៩(១) និងវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង[47]។

---

[44] ចម្លើយតប កំណត់សម្គាល់ជើងទំព័រ ៥៥ (នៃកថាខណ្ឌ ១៩) យោងដល់អង្គជំនុំជម្រះតុលាការកំពូល ដែលដកស្រង់សេចក្តីសម្រេចលើ "បណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីសំណើសុំឱ្យមានចំណាត់ការជាបន្ទាន់ តាមវិធាន ៣៥" ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៣ ឯកសារ **E189/3/1/8** កថាខណ្ឌ ២១ និងកថាខណ្ឌ ២៦។

[45] បណ្តឹងសាទុក្ខ កថាខណ្ឌ ៥៦ និងកំណត់សម្គាល់ជើងទំព័រ ៣៣។

[46] ចម្លើយតប កថាខណ្ឌ ២២ និងកថាខណ្ឌ ៥។

[47] ចម្លើយតប កថាខណ្ឌ ២២ និងកំណត់សម្គាល់ជើងទំព័រ ៥៨-៦០។

៤២. ជាដំបូង មេធាវីការពារក្ដីពុំបានព្រងើយកន្តើយសោះឡើយ ផ្ទុយទៅវិញ មេធាវីការពារក្ដីបានពន្យល់យ៉ាងវែង នៅក្នុងបណ្ដឹងសាទុក្ខរបស់ខ្លួនថា "ការបញ្ជាក់" នេះ របស់អង្គជំនុំជម្រះ ដែលបានលើកឡើងតែវិធាន ១០៧(៤) នៃវិធានផ្ទៃក្នុង និងមាត្រា ៨.៥ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ គឺមិនត្រឹមត្រូវ[48]។

៤៣. បន្ទាប់មក ការយោងរបស់សហព្រះរាជអាជ្ញា លើវិធាន ១០១(៦)(ឈ) វិធាន ៣៩(១) និងវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង ធ្វើឲ្យមានភាពច្របូកច្របល់។ ការយោងនោះមានន័យថា តាមសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសាលាដំបូង "ត្រូវតែបញ្ចូលនូវសេចក្ដីថ្លែង" អំពីពេលវេលាកំណត់សម្រាប់ប្ដឹងសាទុក្ខ ហើយអង្គជំនុំជម្រះក៏អាចកំណត់ និងពន្យារពេលវេលាកំណត់ សម្រាប់ធ្វើបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម។[49]

៤៤. ក៏ប៉ុន្តែ វិធាន ១០១(៦)(ឈ) ចែងថា "សាលក្រមត្រូវមានចុះសេចក្ដីដូចខាងក្រោម៖ (...) ឈ-សិទ្ធិប្ដឹងសាទុក្ខរបស់ភាគី និងលក្ខខណ្ឌ និងពេលវេលាកំណត់សម្រាប់ប្ដឹងសាទុក្ខ" នៅចុងក្រោយនៃបញ្ជីនៃសេចក្ដីផ្សេងទៀត ដូចជា កាលបរិច្ឆេទនៃសវនាការ កាលបរិច្ឆេទនៃការប្រកាសសាលក្រម ឈ្មោះរបស់ចៅក្រមដែលជំនុំជម្រះ ឈ្មោះរបស់សហព្រះរាជអាជ្ញា ឈ្មោះរបស់ក្រឡាបញ្ជី ឈ្មោះរបស់ជនជាប់ចោទ ឈ្មោះរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងឈ្មោះរបស់មេធាវី (វិធាន ១០១(៦)(ក)-(ឈ))។ គ្មានសេចក្ដីណាមួយបង្កប់នូវអំណាចឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។ ការបញ្ជាក់អំពីផ្លូវឧបាស្រ័យ ក៏ដូចជាកាលបរិច្ឆេទ និងឈ្មោះ មានគោលដៅតែមួយគត់ គឺដើម្បីរម្លឹកអំពីអត្ថិភាពនៃសិទ្ធិប្ដឹងសាទុក្ខ (និងការពន្លាតសច្ចធារណ៍និរទោសរហូតដល់ពេលសាលក្រមចូលជាស្ថាពរ)។

៤៥. ក្នុងសាលក្រមសំណុំរឿង ០០២/០១ (ដែលបានប្រកាស និងចេញជាលាយលក្ខណ៍អក្សរ នៅក្នុងថ្ងៃតែមួយ) អង្គជំនុំជម្រះបានចង្អុលបង្ហាញថា៖ "សាលក្រមនេះបើកផ្លូវឲ្យភាគីប្ដឹងសាទុក្ខ តាមការកំណត់នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក"។[50] ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះបានបញ្ជាក់ថា៖ "សាលក្រមនេះប្រកាសជាសាធារណៈ នៅក្នុងសាលសវនាការធំ នៃ អ.វ.ត.ក នៅថ្ងៃទី១៦

[48] បណ្ដឹងសាទុក្ខ កថាខណ្ឌ ១៣-២០។

[49] ចម្លើយតប កំណត់សម្គាល់ជើងទំព័រ ៥៨ និង ៦០ (នៃកថាខណ្ឌ ២២)។

[50] សាលក្រម សំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ **E313** ទំព័រ ៩៨០។

ខែវិច្ឆិកា ឆ្នាំ២០១៨ ហើយបើកផ្លូវឲ្យភាគីប្តឹងសាទុក្ខ តាមការកំណត់នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក"។[51] បន្ទាប់មក អង្គជំនុំជម្រះបានផ្តល់ "ការបំភ្លឺ" ឬ "ការបញ្ជាក់" មិនត្រឹមត្រូវ លើពេលចាប់ផ្តើមគិតកាលកំណត់ធ្វើបណ្តឹងសាទុក្ខ។[52] ដូច្នេះ អង្គជំនុំជម្រះមិនចង់កំណត់ ឬពន្យារកាលកំណត់ធ្វើបណ្តឹងសាទុក្ខទេ គឺគ្រាន់តែរម្លឹកថា សាលក្រមបើកផ្លូវឲ្យភាគីប្តឹងសាទុក្ខ តាមការកំណត់នៃវិធានផ្ទៃក្នុង និងចង់ផ្តល់ការបំភ្លឺ ឬការបញ្ជាក់លើពេលចាប់ផ្តើមកាលកំណត់ធ្វើបណ្តឹងសាទុក្ខ ដោយអានវិធានផ្ទៃក្នុងច្រឡំ។ ការមិនលើកឡើងអំពីវិធាន ៣៩ បង្ហាញថា អង្គជំនុំជម្រះមិនចង់ច្បាមយកអំណាចដែលខ្លួនមិនមានឡើយ។

៤៦. ថ្វីត្បិតតែវិធាន ៣៩ នៃវិធានផ្ទៃក្នុង អនុញ្ញាតឲ្យចៅក្រមកំណត់ ឬពន្យារពេលវេលា ក៏ដោយ ក៏វិធាននេះមិនអនុញ្ញាតឲ្យចៅក្រមកំណត់ ឬពន្យារពេលវេលាបានឡើយ ប្រសិនបើពួកគាត់ទាំងនោះគ្មានសមត្ថកិច្ចក្នុងការធ្វើបែបនេះ។ ច្បាស់ណាស់ វិធាននេះមិនអនុញ្ញាតឲ្យចៅក្រមសម្រេចក្រៅពីក្របខណ្ឌនៃកិច្ចដំណើរការនីតិវិធី ដែលពួកគាត់បានទទួលបណ្តឹងឡើយ។

៤៧. អង្គជំនុំជម្រះចាត់ការលើនីតិវិធីនៅជាន់ដំបូង ហើយទោះជាក្នុងករណីណាក៏ដោយ ខ្លួនមិនអាចចាត់ការលើនីតិវិធីប្តឹងសាទុក្ខបានឡើយ គឺមានតែអង្គជំនុំជម្រះតុលាការកំពូលមួយគត់ទើបមានយុត្តាធិការ។ ដូចគ្នាផងដែរ នៅដំណាក់កាលស៊ើបសួរ មានតែអង្គបុរេជំនុំជម្រះមួយគត់ទើបអាចធ្វើអន្តរាគមន៍បាន ពាក់ព័ន្ធនឹងកាលកំណត់ធ្វើបណ្តឹងឧទ្ធរណ៍ គឺមិនមែនចៅក្រមស៊ើបអង្កេតទេ។

៤៨. ក្នុងរឿងក្តីនេះ សាលក្រមបើកផ្លូវឲ្យភាគីប្តឹងសាទុក្ខ តាមការកំណត់នៃវិធានផ្ទៃក្នុង ពោលគឺ ក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសសាលក្រម[53]។ ដូចការអះអាងខុសរបស់សហព្រះរាជអាជ្ញា ក្នុងកថាខណ្ឌដែលខ្លួនផ្តល់ជូនអង្គជំនុំជម្រះនូវអំណាចក្នុងការកំណត់ ឬពន្យាររយៈពេលធ្វើបណ្តឹងសាទុក្ខ បើលោក ខៀវ សំផន ចង់ពន្យារពេល គាត់អាចស្នើសុំទៅអង្គជំនុំជម្រះតុលាការកំពូល អនុលោមតាមវិធាន ៣៩។[54]

---

[51] ប្រតិចារឹក ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E1/529.1** ម៉ោង ១១ និង ៣៨ នាទី (ឃ្លានេះមានតែនៅក្នុងប្រតិចារឹកជាភាសាខ្មែរ និងអង់គ្លេសប៉ុណ្ណោះ មិនមានជាភាសាបារាំងទេ)។

[52] ប្រតិចារឹក ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E1/529.1** ម៉ោង ១១ និង ៣៨ នាទី (ទំព័រ ៥៧ ជាភាសាអង់គ្លេស ទំព័រ ៦៨ ជាភាសាបារាំង)។

[53] បណ្តឹងសាទុក្ខ កថាខណ្ឌ ១៥-១៦។

[54] ចម្លើយតប កថាខណ្ឌ ២២។

៤៩. ប្រហែលជាមិនអត់ប្រយោជន៍ទេដែលមករម្លឹកថា សហព្រះរាជអាជ្ញាមិនមែនល្ងីល្ងើនោះទេ។ មេធាវីការពារក្ដីក៏មិនល្ងីល្ងើដូចគ្នាដែរ។ ប្រសិនបើមេធាវីការពារក្ដីគោរពយ៉ាងងងឹតងងល់តាមការបញ្ជាក់ខុសរបស់អង្គជំនុំជម្រះ ហើយរង់ចាំរហូតដល់ពេលជូនដំណឹងអំពីសំអាងហេតុជាលាយលក្ខណ៍អក្សរជាភាសាខ្មែរ និងបារាំង ទើបធ្វើបណ្ដឹងសាទុក្ខនោះ សហព្រះរាជអាជ្ញាច្បាស់ជានឹងលើកឡើងអំពីភាពមិនអាចទទួលយកបាននៃបណ្ដឹងសាទុក្ខ ដោយអះអាងយ៉ាងសមហេតុផលថា បណ្ដឹងសាទុក្ខត្រូវបានដាក់យឺតពេល។ មេធាវីការពារក្ដីពិតជាមិនប្រថុយប្រថាន ឬធ្វេសប្រហែសបែបនេះឡើយ។[55]

៥០. មេធាវីការពារក្ដីក៏មានករណីយកិច្ចលាតត្រដាងអំពីព្យសនកម្មធ្ងន់ធ្ងរដែលលោក ខៀវ សំផន បានទទួលរង ហើយសហព្រះរាជអាជ្ញាព្យាមយាមលាក់បាំង។

## ៣. ការប៉ុនប៉ងលាក់បាំងព្យសនកម្មរបស់លោក ខៀវ សំផន

៥១. បើជឿតាមសហព្រះរាជអាជ្ញា លោក ខៀវ សំផន មិនទទួលរងព្យសនកម្មអ្វីទេ ហើយគាត់ត្រូវអរគុណអង្គជំនុំជម្រះទៀតផង ចំពោះ "ការចេញសេចក្ដីសង្ខេបសាលក្រម មុនពេលដែលកាលបរិច្ឆេទសម្រាប់បណ្ដឹងសាទុក្ខចាប់ផ្ដើមរាប់" ពីព្រោះ "តាមរយៈការចេញសេចក្ដីសង្ខេបសាលក្រមមួយ អង្គជំនុំជម្រះសាលាដំបូងបានផ្ដល់ដល់ ខៀវ សំផន នូវពេលវេលាកាន់តែច្រើនថែមទៀត ដើម្បីចាប់ផ្ដើមត្រៀមរៀបចំដំណាក់កាលបណ្ដឹងសាទុក្ខនៃកិច្ចដំណើរការនីតិវិធី"។[56]

៥២. លោក ខៀវ សំផន ចង់ដឹងអំពីក្បួន (សម្ងាត់) របស់សហព្រះរាជអាជ្ញា ដើម្បីស្វែងរកសារៈប្រយោជន៍នៃសេចក្ដីសង្ខេប ដែល (ខុសពីផ្នែកសម្រេចសេចក្ដី) ពុំមានអានុភាពអ្វីទេ។[57] សហព្រះរាជអាជ្ញាគេចវេសមិនព្រមពន្យល់ថា ហេតុអ្វីបានជាការដែលអង្គជំនុំជម្រះបាន "គូសបញ្ជាក់អំពី

[55] បណ្ដឹងសាទុក្ខ កថាខណ្ឌ ៥៣-៥៤។

[56] ចម្លើយតប កថាខណ្ឌ ១ និងកថាខណ្ឌ ២២។

[57] បណ្ដឹងសាទុក្ខ កថាខណ្ឌ ៦១, ចម្លើយតប កថាខណ្ឌ ៣។

ចំណុចដែលបានរកឃើញសំខាន់ៗ"របស់អង្គជំនុំជម្រះ[58] អាចឲ្យលោក ខៀវ សំផន "ចាប់ផ្ដើមត្រៀមរៀបចំដំណាក់កាលបណ្ដឹងសាទុក្ខ"របស់គាត់[59] បាន។

៥៣. ទោះបីជាខិតខំស្វែងរកក្នុងសេចក្ដីសង្ខេបយ៉ាងណាក៏ដោយ ក៏មេធាវីការពារក្ដីរកមិនឃើញទាល់តែសោះថា តើអង្គជំនុំជម្រះផ្អែកលើមូលដ្ឋានអ្វី ដើម្បីឈានដល់ការធ្វើសេចក្ដីសន្និដ្ឋានលើអង្គហេតុ និងអង្គច្បាប់។ ដោយមិនអាចកំណត់បានថា តើអង្គជំនុំជម្រះឈានដល់ការធ្វើសេចក្ដីសន្និដ្ឋានបែបនេះតាមរបៀបណា មេធាវីការពារក្ដីអាចត្រឹមតែលេងល្បែងទាយប៉ុណ្ណោះ។ ទោះជាក្នុងករណីណាក៏ដោយ មេធាវីការពារក្ដីមិនអាចរកឃើញកំហុសអង្គច្បាប់ ឬកំហុសអង្គហេតុ ដែលខ្លួនអាចលើកឡើង ដោយមិនទាំងដឹងថាតើអង្គជំនុំជម្រះផ្អែកលើភ័ស្ដុតាង ឬច្បាប់ជាធរមានអ្វីផង។

៥៤. ដូច្នេះ លោក ខៀវ សំផន នឹងមិនអរគុណដល់អង្គជំនុំជម្រះ ចំពោះការចេញសេចក្ដីសង្ខេបនៃសាលក្រមនោះទេ។ លោក ខៀវ សំផន ក៏នឹងមិនអរគុណដល់អង្គជំនុំជម្រះ ចំពោះការរំលោភលើសិទ្ធិខាងនីតិវិធី សិទ្ធិទទួលបានតម្លាភាពនៃកិច្ចដំណើរការនីតិវិធី សិទ្ធិទទួលបានសច្ចភាពផ្លូវច្បាប់ សិទ្ធិធ្វើបណ្ដឹងសាទុក្ខ និងសិទ្ធិទទួលបានការកាត់សេចក្ដីលើរឿងក្ដីរបស់ខ្លួន នោះដែរ។

៥៥. ទោះបីជាសហព្រះរាជអាជ្ញាចង់និយាយយ៉ាងម៉េចក៏ដោយ មេធាវីការពារក្ដីមិនមែនប្ដឹងសាទុក្ខប្រឆាំងនឹងទម្រង់ការនៃសាលក្រម ក៏ព្រោះតែខ្លួនរីករាយនឹងរិះគន់អង្គជំនុំជម្រះនោះទេ[60]។ មេធាវីការពារក្ដីបានប្ដឹងសាទុក្ខប្រឆាំងនឹងទម្រង់ការនៃសាលក្រម ក៏ព្រោះតែអង្គជំនុំជម្រះបានរំលោភលើច្បាប់របស់ អ.វ.ត.ក និងបានផ្ដន្ទាទោសលោក ខៀវ សំផន ជាសាធារណៈ ហើយធ្វើឲ្យគាត់គ្មានលទ្ធភាពប្ដឹងសាទុក្ខលើអង្គសេចក្ដីប្រឆាំងនឹងការផ្ដន្ទាទោសលើរូបគាត់ ពីព្រោះគាត់មានអាយុ ៨៧ឆ្នាំ ទៅហើយ ហើយគាត់អាចនឹងស្លាប់នៅថ្ងៃស្អែកក៏ថាបាន។ មេធាវីការពារក្ដីបានប្ដឹងសាទុក្ខប្រឆាំងនឹងទម្រង់ការនៃសាលក្រម ពីព្រោះទង្វើរបស់អង្គជំនុំជម្រះមានភាពធ្ងន់ធ្ងរណាស់។ ការប៉ុនប៉ងរបស់សហព្រះរាជអាជ្ញាក្នុងការបំភាន់ឲ្យគេជឿផ្ទុយពីនេះ រឹតតែបញ្ជាក់ថា អង្គជំនុំជម្រះពិតជាធ្វើខុសមែន។

---

[58] ចម្លើយតប កថាខណ្ឌ ៣។

[59] ចម្លើយតប កថាខណ្ឌ ២២។

[60] សូមមើលខាងលើ កំណត់សម្គាល់ជើងទំព័រ ១១ (នៃកថាខណ្ឌ ៩)។

៥៦. ជារួម អ្វីដែលសហព្រះរាជអាជ្ញាបានអះអាង នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល និងប្រជាជនកម្ពុជា គឺមានន័យថា នៅ អ.វ.ត.ក អ្វីក៏អាចធ្វើទៅបានដែរ។ អង្គជំនុំជម្រះកាត់សេចក្តីលើឧក្រិដ្ឋកម្មដែលធ្ងន់ធ្ងរបំផុត ខ្លួនមានអំណាចគ្រប់យ៉ាង ហើយវាមិនសំខាន់ទេ បើខ្លួនអង្គុយលើវិធានច្បាប់របស់ អ.វ.ត.ក ដោយធ្វើតាមតែអំពើចិត្ត ខណៈដែលជនជាប់ចោទមិនអាចដឹងបានថាវិធានច្បាប់ណាមួយនឹងយកមកអនុវត្តចំពោះខ្លួន។

៥៧. ផ្ទុយទៅវិញ អ.វ.ត.ក ត្រូវបានសន្មតថាជាតុលាការគំរូមួយ សម្រាប់សហគមន៍អន្តរជាតិ និយាយជារួម និងសម្រាប់ប្រទេសកម្ពុជា និយាយដោយឡែក។ ម្ចាស់ជំនួយមិនមែនចំណាយប្រាក់រាប់លានដុល្លារ ដើម្បីឱ្យ អ.វ.ត.ក ធ្វើជាគំរូនៃភាពតាមទំនើងចិត្តនោះឡើយ។ អ្នកបង្កើត អ.វ.ត.ក បានជ្រើសយកការកំណត់វិធានច្បាស់លាស់អំពីទម្រង់ការនៃសាលក្រម និងកាលកំណត់ធ្វើបណ្តឹងសាទុក្ខ។ វិធានទាំងនេះខុសពីវិធានជាធរមាន នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ពីព្រោះវាកើតចេញពីប្រព័ន្ធច្បាប់ខុសគ្នា និងក៏ប្រហែលជាដោយសារតែវ័យចាស់ជរារបស់ជនដែលត្រូវបានចោទប្រកាន់ និងជំនុំជម្រះ នៅ អ.វ.ត.ក រយៈពេល ៤០ ឆ្នាំ ក្រោយអង្គហេតុ។ វិធានទាំងនេះប្រហែលជាត្រូវបានកំណត់ តាមរបៀបមួយ ដើម្បីផ្តល់ជាគំរូល្អដល់តុលាការកម្ពុជា[61]។ ទោះជាយ៉ាងណាក៏ដោយ វិធានទាំងនេះជាវិធានធរមានតែមួយគត់សម្រាប់លោក ខៀវ សំផន ហើយអង្គជំនុំជម្រះត្រូវតែគោរពតាម។

៥៨. **<u>អាស្រ័យហេតុនេះ</u>** មេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះតុលាការកំពូលមេត្តា៖

- **សម្រេច**ជាបន្ទាន់
- **ប្រកាស**ទទួលយកបណ្តឹងសាទុក្ខ
- **ធ្វើមោឃភាព**សាលក្រម ដែលបានប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨

[61] "អ.វ.ត.ក ត្រូវបានបង្កើតឡើងនៅប្រទេសកម្ពុជា ដើម្បីបង្កើនសមត្ថភាពរបស់តុលាការជាតិ ដែលមានកម្រិតទាប នៅក្នុងការរស់រវែងឯករាជ្យភាពលើសកលលោក និងត្រូវគេល្បីថា ចេញសាលក្រមសង្ខេប ដោយគ្មានសំអាងហេតុ"៖ ការជំនុំជម្រះក្តីមួយទៀត - ការពិនិត្យមើលឡើងវិញសំណុំរឿង ០០២/០២៖ ការជំនុំជម្រះក្តីលើកទីពីរលើ នួន ជា និង ខៀវ សំផន នៅ អ.វ.ត.ក ដោយ Caitlin McCaffrie និង Daniel Mattes សំណៅកែសម្រួល បោះពុម្ពផ្សាយថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ របាយការណ៍ជូនមជ្ឈមណ្ឌលសិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ WSD Handa នៅសាកលវិទ្យាល័យ ស្ទែនហ្វ័ដ និងមជ្ឈមណ្ឌលបូព៌ា-បស្ចិម (https://krttrialmonitor.files.wordpress.com/2018/11/anothertrial_c00202report_mccaffriemattes_112018.pdf.)។

- **ទទួលស្គាល់**អសុពលភាពនៃសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរ ដែលនឹងចេញនាពេលខាងមុខ

*បើមិនដូច្នេះទេ*

- **លើកពេល**ចាប់ផ្តើមកាលកំណត់បណ្តឹងសាទុក្ខ ចាប់ពីពេលជូនដំណឹងអំពីសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សររបស់អង្គជំនុំជម្រះ ជាបីភាសាផ្លូវការរបស់ អ.វ.ត.ក ឬចាប់ពីពេលជូនដំណឹងអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ប្រសិនបើសេចក្តីសម្រេចនេះចេញនៅពេលក្រោយ។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ | រាជធានីភ្នំពេញ<br><br>ទីក្រុងប៉ារីស | |